# សេចក្តីថ្លែងការណ៍របស់សហភាពអឺរ៉ុបក្នុងស្រុកស្តីពី ការបិទសារព័ត៌មាន The Cambodia Daily

ដោយមានការឯកភាពជាមួយប្រមុខបេសកកម្មការទូតរបស់សហភាពអឺរ៉ុបនៅកម្ពុជា ប្រតិភូសហភាពអឺរ៉ុប សូមចេញនូវសេចក្តីថ្លែងការណ៍ដូចខាងក្រោម៖

ការបិទដោយបង្ខំនូវសារព័ត៌មាន The Cambodia Daily គឺជាការប៉ះពាល់ធ្ងន់ធ្ងរទៅដល់ភាពចម្រុះនៃបណ្តាញផ្សព្វផ្សាយព័ត៌មានរបស់ប្រទេសកម្ពុជា។ ដូចដែលបានលើកឡើងនៅក្នុងសេចក្តីថ្លែងការណ៍របស់អ្នកនាំពាក្យរបស់តំណាងជាន់ខ្ពស់/អនុប្រធានសហភាពអឺរ៉ុបកាលពីថ្ងៃទី០៣ ខែកញ្ញា កន្លងទៅ ដំណើរការប្រជាធិបតេយ្យគួរជាទីទុកចិត្ត ឆ្ពោះទៅរកការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនៅក្នុងខែកក្កដា ឆ្នាំ២០១៨ ខាងមុខ តម្រូវឲ្យមានពហុនិយមនៅក្នុងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ក៏ដូចជានៅក្នុងចំណោមគណបក្សនយោបាយផងដែរ។ យើងរំពឹងថា អាជ្ញាធរកម្ពុជានឹងអនុញ្ញាតឲ្យសារព័ត៌មាន The Cambodia Daily និងអង្គភាពផ្សព្វផ្សាយព័ត៌មានដែលរងការប៉ះពាល់ផ្សេងៗទៀតអាចដំណើរការឡើងវិញនិងបន្តប្រតិបត្តិការរបស់ខ្លួនបាន ទន្ទឹមនឹងនោះ បញ្ហាបង់ពន្ធដារ និងបញ្ហាផ្សេងៗទៀត ត្រូវដោះស្រាយតាមរយៈដំណើរការតាមច្បាប់សមស្របណាមួយ។

ភ្នំពេញ ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៧